ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# កំណត់ហេតុ
# មហាសន្និបាតភាគហ៊ុនិកលើកទី៣

**ក/.កាលបរិច្ឆេទ** ៖ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ ចាប់ពីម៉ោង៩:០០ព្រឹក

**ខ/.ទីកន្លែង** ៖ សាលប្រជុំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

**គ/.សមាសភាពចូលរួម** ៖

- គណៈអធិបតី ៖
  ១. ឯកឧត្តម សឹម ណារ៉ា — ប្រធានក្រុមប្រឹក្សាភិបាល
  ២. ឯកឧត្តម ស៊ឹម ស៊ីថា — អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  ៣. ឯកឧត្តម ឃួង ស្រេង — សមាជិកក្រុមប្រឹក្សាភិបាល-តំណាងសាលារាជធានីភ្នំពេញ
  ៤. លោកស្រី ងិន ចន្ទ្រា — សមាជិកក្រុមប្រឹក្សាភិបាល - តំណាងនិយោជិត
  ៥. លោកឧកញ៉ា ចាង យុនហៀង — សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន
  ៦. លោក អោម សេងបូ៉ា — សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលឯករាជ្យ
- ភ្ញៀវកិត្តិយស ៖
  ១. ឯកឧត្តម សយ ភីរម្យ — អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម
  ២. ឯកឧត្តម នេត មុន្នី — មន្ត្រីត្រួតពិនិត្យរដ្ឋ អមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  ៣. លោកស្រី នាន បូនី — តំណាងគណៈកម្មការមូលបត្រកម្ពុជា
  ៤. កញ្ញា ទ្រី ស៊ីណា — តំណាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  ៥. លោក Lee Ken Wai — តំណាងក្រុមហ៊ុនសវនកម្ម BDO (Cambodia) Ltd
  ៦. លោក ឡេង វឌ្ឍនៈ — តំណាងធនាគារអេស៊ីលីដា ភីអិលស៊ី ។

- លេខាកត់ត្រា ៖ លោកបណ្ឌិត ជា វិសុទ្ធ អគ្គនាយករងទទួលបន្ទុកជាលេខាសហគ្រាស និង លោក ហួត សុខហេង នាយលេខាធិការដ្ឋាន។
- អ្នកចូលរួម ៖ ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះនៅភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ រ.ទ.ស.ភ (ធនាគារអេស៊ីលីដា ភីអិលស៊ី) ដើម្បីត្រៀមចូលរួមមហាសន្និបាតមានចំនួន ១២៩នាក់ គិតជាភាគហ៊ុនមានចំនួន៧៩.២១៦.១៥២ហ៊ុន ស្មើនឹង៩១%នៃភាគហ៊ុនធម្មតាសរុប។ ភាគហ៊ុនិកដែលបានចុះវត្តមាននិងបានចូលរួមមហាសន្និបាតជាក់ស្តែងមានចំនួន៨១នាក់ គិតជាភាគហ៊ុនមានចំនួន ៧៥.០៤៣.២៥២ហ៊ុន (ស្មើនឹង ៩៥%នៃចំនួនភាគហ៊ុនដែលបានចុះឈ្មោះចូលរួម) ក្នុងនោះលោក ជូ វណ្ណៈ អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រៅពីនេះ មានភាគហ៊ុនិកមួយចំនួនទៀតបានចូលរួម ដោយពុំបានចុះឈ្មោះនៅភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

**ឃ/.ដំណើរការនៃមហាសន្និបាត**

**១/.បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០១៤ និងទិសដៅអាជីវកម្មឆ្នាំ២០១៥**

លោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ បានធ្វើរបាយការណ៍ជូនអង្គមហាសន្និបាតជ្រាបពីលទ្ធផលអាជីវកម្មឆ្នាំ២០១៤ និងទិសដៅអាជីវកម្មឆ្នាំ២០១៥ តាមរយៈការបញ្ចាំងស្លាយជាភាសាខ្មែរ និងភាសាអង់គ្លេស ដោយមានគោលខ្លឹមសារសំខាន់ៗ ដូចមានក្នុងឯកសារសម្រាប់មហាសន្និបាត។ លោកក៏បានធ្វើការកត់សម្គាល់ផងដែរថា ៖

- ក្នុងសម័យប្រជុំលើកទី១៤ កាលពីថ្ងៃទី២៧ខែមីនាឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលអាណត្តិទី៥ បានអនុម័តបែងចែកភាគលាភឆ្នាំ២០១៤ ជាសាច់ប្រាក់ (Cash Dividend) ក្នុងមួយភាគហ៊ុន ១០៥.២០រៀល គឺកើនទ្វេដងលើភាគលាភឆ្នាំ២០១៣ (៥៤,៧៤រៀល)។ ភាគលាភនេះ បានឈានដល់កម្រិតស្តង់ដារថ្នាក់អន្តរជាតិ (Dividend Yield ២%)។
- ក្រុមប្រឹក្សាភិបាលបានអនុម័តបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលចំនួន២គឺ គណៈកម្មាធិការសវនកម្ម ដែលមានលោក អោម សេងបូរ៉ា ជាប្រធាន និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលមានឯកឧត្តម ម៉ី វ៉ាន់ ជាប្រធាន។ ក្រៅពីនេះ ក៏មានការតែងតាំងអគ្គនាយិការង១រូបបន្ថែម គឺលោកស្រី ងិន ចន្ទ្រា ដើម្បីទទួលបន្ទុកការងារអាជីវកម្ម។
- ជារួម ក្នុងឆ្នាំ២០១៤ រ.ទ.ស.ភ ផលិតទឹកស្អាតសរុប១៤៩.៥៥២.០៩៥ម៣, ដាក់បំពង់ចែកចាយបានប្រវែង១៦១គ.ម និងបានរក្សាអត្រាទឹកបាត់បង់ឱ្យស្ថិតក្នុងរង្វង់៧%។ ទន្ទឹមគ្នានោះ តបណ្តាញជូនអតិថិជនបានចំនួន១៩.៧២០បណ្តាញ ក្នុងនោះអតិថិជនចំណូលទាបមានចំនួន១.១៤៩បណ្តាញ។ អត្រាប្រមូលប្រាក់ថ្លៃទឹកអនុវត្តបាន៩៩,៩០%។ ក្រៅពីនេះ ចំណូលសរុបប្រចាំឆ្នាំ គឺប្រមាណ១៥៦,៥ពាន់លានរៀល កើនលើសឆ្នាំ២០១៣ ប្រមាណ៣% ដែលជាហេតុធ្វើឱ្យប្រាក់ចំណេញពិតកើនលើសឆ្នាំកន្លងទៅ ២០%។ ជាមួយកំណើនប្រាក់ចំណេញនេះ រ.ទ.ស.ភ បានបង្កើនមូលធនពី៦៩៥ពាន់លានរៀលក្នុងឆ្នាំ២០១៣ មកដល់៧៣៦ពាន់លានរៀល។
- បណ្តាសន្ទស្សន៍សំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០១៤ គឺ ៖

| | | |
|---|---|---|
| ១. | អនុបាតចរន្ត | ៤,៩២ ដង |
| ២. | អត្រាអនុបាតចរន្តលឿន | ៤,២៣ ដង |
| ៣. | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៤,០៤% |
| ៤. | ផលចំណេញក្នុងមួយឯកតាមូលធន | ៦,៣៩% |
| ៥. | ចំណេញក្នុងមួយឯកតាកម្មសិទ្ធិ | ៥២៦ រៀល |
| ៦. | ភាគលាភក្នុងមួយឯកតាកម្មសិទ្ធិ | ១០៥.២០ រៀល |

- ទិសដៅសំខាន់ៗនៃអាជីវកម្មក្នុងឆ្នាំ២០១៥ គឺ ៖

| | | |
|---|---|---|
| ១. | តបណ្តាញចូលផ្ទះថ្មីចំនួន | ១៦.០០០ បណ្តាញ |
| ២. | ចំនួនអតិថិជនចុងគ្រានាដំណាច់ឆ្នាំ២០១៥ | ២៨២.៥១០ បណ្តាញ |
| ៣. | បរិមាណទឹកលក់ | ១៤៦.៧៥៨.៤០០ ម៣ |
| ៤. | បរិមាណទឹកផលិត | ១៥៧.៨០៤.៦០០ ម៣ |
| ៥. | អត្រាធ្វើវិក្កយបត្រ | ៩៣,០០% |
| ៦. | អត្រាទារប្រាក់ | ៩៩,៩០% |
| ៧. | ថ្លៃទឹកលក់ជាមធ្យម/ម៣ | ១.០២៤ រៀល |

| | | |
|---|---|---|
| ៨. | ចំណូលសរុប | ១៩៦.៧៤៤.៣៧៦.០០០ រៀល |
| ៩. | ចំណាយដំណើរការសហគ្រាស | ១៥២.០១៦.៦៩៤.០០០ រៀល |
| ១០. | ចំណេញពិត | ៤៤.០៧៧.៦៧៦.០០០ រៀល។ |

## ២/. សំណួរ-ចម្លើយ

មានតែអ្នកចូលរួមម្នាក់គត់ បានចោទសួរ និងលើកសំណូមពរដូចខាងក្រោម ៖

*ក- សូមពន្យល់ពីចំណូលពីសេវាកម្មសាងសង់ និងចំណូលផ្សេងៗដែលបានកើនឡើង។*

*ខ- តើ រ.ទ.ស.ភ ប្រើប្រាស់យុទ្ធសាស្ត្រអ្វី ដើម្បីទទួលបានចំណេញពីអត្រាប្តូរប្រាក់?*

*គ- សំណូមពរបញ្ចូលទិន្នន័យលម្អិតអំពីលទ្ធផលហិរញ្ញវត្ថុ ទៅក្នុងឯកសាររបាយការណ៍សម្រាប់មហាសន្និបាតភាគហ៊ុនិក។ ឧទាហរណ៍ករណីចំណូលពីការលក់ គួរបានរៀបរាប់លម្អិតពីប្រភេទរបស់វា (ដូចជាចំណូលពីការលក់ទឹកជូនអតិថិជនដីភាពមានទឹកប្រាក់ចំនួនប៉ុន្មាន និងប្រើប្រាស់ទឹកអស់ប៉ុន្មានម៉ែត្រគូបជាដើម) ព្រោះវាមានសារសំខាន់សម្រាប់វិនិយោគិនក្នុងការសម្រេចចិត្តធ្វើការវិនិយោគ។*

ឆ្លើយតបនឹងសំណួរនេះ លោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ បានបំភ្លឺដូចខាងក្រោម ៖

ក- កម្រៃពីសេវាកម្មសាងសង់មានការកើនឡើង ដោយសារកត្តាសំខាន់២គឺ៖
- កំណើននៃសំណង់បុរីនៅតំបន់មួយចំនួនក្នុងរាជធានីភ្នំពេញ ដែលស្នើសុំដាក់បំពង់ទឹកចូលទីតាំងសំណង់របស់ខ្លួន ដោយត្រូវបង់ថ្លៃវិនិយោគ។
- ចំណូលពីសាខាសេវាកម្មទឹកស្អាតនិងអនាម័យ ដែលបច្ចុប្បន្ននេះកំពុងទទួលម៉ៅការពីអង្គការ JICA នូវគម្រោងដាក់បំពង់នៅខេត្តបាត់ដំបង និងកំពង់ចាម។ ចំណូលពីសេវាកម្មនេះត្រូវបង់ចូល រ.ទ.ស.ភ ។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ សាខាបានទទួលគម្រោងពេញលេញ ដែលកាលពីដើមឆ្នាំ២០១៤ មានគម្រោងតិចតួច។

ខ- ចំណូលផ្សេងៗកើនឡើង ដោយសារ ៖
- ចំណូលពីការប្រាក់ : រ.ទ.ស.ភ ដាក់សាច់ប្រាក់សន្សំនៅក្នុងគណនីសន្សំមានកាលកំណត់ ជាទូទៅរយៈពេលមួយឆ្នាំ ក្នុងអត្រា៥ទៅ៦ភាគរយ នៅតាមបណ្តាធនាគារធំៗ ដូចជាកាណាឌីយ៉ា, អ អេច បី ឥណ្ឌូចៃណា (HRB Indochina Bank) និង វឌ្ឍនៈ។
- ចំណេញពីអត្រាប្តូរប្រាក់ ដោយសារ រ.ទ.ស.ភ ទទួលហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍជាប្រាក់អឺរ៉ូ ហើយបច្ចុប្បន្នតម្លៃប្រាក់អឺរ៉ូធ្លាក់ចុះ។ រ.ទ.ស.ភ រក្សាសាច់ប្រាក់ជាដុល្លា ដែលពេលទូទាត់ហិរញ្ញប្បទាន ធ្វើឱ្យមានចំណេញអត្រាប្តូរប្រាក់។

គ- លោក រស់ គឹមលាង បានថ្លែងអំណរគុណចំពោះសំណូមពរនេះ និងសន្យាធ្វើការកែលម្អរបាយការណ៍សម្រាប់មហាសន្និបាតលើកក្រោយ។

## ៣/. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ

ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈអធិបតីភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងភាគហ៊ុនិកទាំងអស់ ដែលបានអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី៣។

ឯកឧត្តមបានគូសបញ្ជាក់ថា គោលបំណងនៃមហាសន្និបាតនេះ គឺដើម្បីពិនិត្យមើលលទ្ធផលអាជីវកម្មដែល រ.ទ.ស.ភ សម្រេចបានក្នុងឆ្នាំ២០១៤ និងទិសដៅអនុវត្តឆ្នាំ២០១៥។ ជោគជ័យនៃអាជីវកម្មនេះ កើតចេញពីការខិតខំ

ប្រឹងប្រែងរបស់មន្ត្រី-និយោជិត និងថ្នាក់ដឹកនាំអង្គភាព ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដ៏ឈ្លាសវៃ និងក្រោមការដឹកនាំរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក៏ដូចជា **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាល ព្រមទាំងក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ ។ លើសពីនេះ រ.ទ.ស.ភ ក៏ត្រូវបានទទួលស្គាល់ពីសំណាក់អន្តរជាតិ ទៅលើគុណភាព និងភាពជាអ្នកដឹកនាំ ព្រមទាំងការគ្រប់គ្រងអង្គភាព។ ជាក់ស្តែងក្នុងឆ្នាំ២០១៤ កន្លងមក រ.ទ.ស.ភ បានទទួលពានរង្វាន់ចំនួន៦ ដែលបញ្ជាក់ពីគុណភាព និងការដឹកនាំប្រកបដោយភាពវៃឆ្លាត។ នេះគឺជាសមិទ្ធិផលដ៏ត្រចះត្រចង់របស់ រ.ទ.ស.ភ ហើយ រ.ទ.ស.ភ នៅតែបន្តអនុវត្តយុទ្ធសាស្ត្រទាំងឡាយដែលបានដាក់ចេញ។

ជាកិច្ចបញ្ចប់នៃមហាសន្និបាត ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានថ្លែងអំណរគុណចំពោះគណៈអធិបតី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងសមាជិកនៃអង្គសន្និបាតទាំងមូល ដែលបានអញ្ជើញចូលរួម និងបានខិតខំបំពេញភារកិច្ចរបស់ខ្លួន ធ្វើឱ្យមហាសន្និបាតភាគហ៊ុនិកលើកទី៣របស់ រ.ទ.ស.ភ ប្រព្រឹត្តទៅដោយជោគជ័យ។

មហាសន្និបាតបានបញ្ចប់នាម៉ោង១០:៣០នាទីព្រឹក នៃថ្ងៃនិងខែឆ្នាំដដែល។

**លេខាធិការសហគ្រាស**

បណ្ឌិត **ជា ទិសុត្ថ**

**ប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត**
**ប្រធានក្រុមប្រឹក្សាភិបាល**

**ស៊ឹម ណារ៉ា**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- គណៈកម្មការមូលបត្រកម្ពុជា

  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

  *"ដើម្បីមុខការ"*
- ឯកសារនិងកាលប្បវត្តិ។